កែសម្រួលតាមការពិភាក្សាផ្ទៃក្នុងអគ្គនាយកដ្ឋានធនធានរ៉ែ ០៥/១២/២០០៦

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ................ អនក្រ

# អនុក្រឹត្យ
## ស្តីពី
## នីតិវិធីនៃការព្យួរទុក និងការដកហូតអាជ្ញាប័ណ្ណធនធានរ៉ែ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សម្រេច

**មាត្រា ១ :**

គ្រប់ប្រភេទអាជ្ញាប័ណ្ណធនធានរ៉ែដែលស្ថិតនៅក្រោមអំណាចនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អាចនឹងត្រូវបានព្យួរទុក ឬដកហូតចំពោះសម្បទានិកណាដែលប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិ ឬច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**មាត្រា ២ :**

ការព្យួរទុក និងការដកហូតអាជ្ញាប័ណ្ណធនធានរ៉ែត្រូវអនុវត្តតាមកម្រិតនៃការប្រព្រឹត្តល្មើសរបស់សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ។ កម្រិតនៃការប្រព្រឹត្តល្មើសរបស់សម្បទានិកត្រូវបែងចែក និងកំណត់ដូចខាងក្រោម :

(១) ធ្វើការស្វែងរុករក និងជីកយករ៉ែនៅក្នុងដីដែលជាកម្មសិទ្ធិឯកជន ដោយគ្មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពីម្ចាស់កម្មសិទ្ធិដី ។

(២) ធ្វើការស្វែងរុករក និងជីកយករ៉ែនៅក្នុងតំបន់ដែលជាកម្មសិទ្ធិរបស់រដ្ឋ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ច ឬស្ថាប័នអន្តរក្រសួងដែលមានតួនាទីគ្រប់គ្រងលើតំបន់នោះ ។

(៣) ធ្វើបុរេសនា ស្វែងរុករក និងជីកយករ៉ែនៅលើដីជាកម្មសិទ្ធិរបស់រដ្ឋដែលបានកំណត់ជាតំបន់វប្បធម៌ ទីតាំងប្រវត្តិសាស្ត្រ និងតំបន់បេតិកភ័ណ្ឌជាតិ ។

(៤) ដាក់បញ្ចាំ ផ្ទេរសិទ្ធិ ឬបន្តជាមរតកនូវអាជ្ញាប័ណ្ណធនធានរ៉ែ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

(៥) មិនរក្សាទុកសៀវភៅកំណត់ត្រា បញ្ជីគណនេយ្យ និងឯកសារពាក់ព័ន្ធ និងមិនផ្តល់ជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលនូវរបាយការណ៍ ឬបញ្ជីដែលទាក់ទងនឹងព័ត៌មានទាំងនោះឱ្យបានត្រឹមត្រូវ និងតាមពេលវេលាកំណត់ ។

(៦) ដឹកនាំធ្វើប្រតិបត្តិការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែមិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុដែលបានលំអិតក្នុងកម្មវិធីការងារស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

(៧) មិនចាត់វិធានការណ៍ឱ្យបានសមស្របដើម្បីការពារបរិស្ថាន លុបអណ្តូងរ៉ែ ការពារសុខភាពនិងសុវត្ថិភាពពលករ និងសាធារណជនដែលនៅក្នុងនិងជុំវិញតំបន់អណ្តូងរ៉ែ ។

(៨) មិនព្រមសងទៅម្ចាស់កម្មសិទ្ធិដីទាំងក្នុង និងក្រៅតំបន់អាជ្ញាប័ណ្ណធនធានរ៉ែនូវការខូចខាតទាំងឡាយណាដែលបណ្តាលមកពីប្រតិបត្តិការធនធានរ៉ែរបស់ខ្លួន ។

(៩) មិនបង់សួយសារលើធនធានរ៉ែដែលជីកយកបាន ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញ ពន្ធអាករពាក់ព័ន្ធ និងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀត ។

(១០) មិនអនុញ្ញាតឱ្យមន្ត្រីដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យរាល់ការងារ និងសកម្មភាពនៅក្នុងការដ្ឋានប្រតិបត្តិការធនធានរ៉ែ ឬតំបន់មានអាជ្ញាប័ណ្ណធនធានរ៉ែរបស់ខ្លួន ។

**មាត្រា ៣ :**

រយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវកំណត់មិនឱ្យលើសពីប្រាំមួយ (០៦) ខែ ។

**មាត្រា ៤ :**

ដោយអនុលោមតាមកម្រិតប្រព្រឹត្តល្មើសរបស់សម្បទានិកដែលកំណត់ក្នុងមាត្រា២ខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវចេញលិខិតណែនាំ ឬបទបញ្ជាមួយជាក់លាក់ ដោយតម្រូវឱ្យសម្បទានិកពាក់ព័ន្ធអនុវត្តតាមការណែនាំ ឬបទបញ្ជានោះក្នុងកំឡុងពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីសម្បទានិកនោះបានទទួលលិខិតណែនាំ ឬបទបញ្ជាពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**មាត្រា ៥ :**

ផុតរយៈពេលដូចបានកំណត់ក្នុងមាត្រា ៤ ខាងលើ ប្រសិនបើសម្បទានិកនោះនៅតែមិនអនុវត្តតាមការណែនាំ ឬបទបញ្ជាទាំងនោះ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវចេញប្រកាសស្តីពីការព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែពីសម្បទានិកនោះ ហើយបិទជាបណ្ដោះអាសន្ននូវរាល់ការងារ និងសកម្មភាពទាំងអស់នៃប្រតិបត្តិការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ ឬកែឆ្នៃធនធានរ៉ែ ។

លោក ប៉េង ណារ៉ុធ បន្ថែមខ្លឹមសារស្តីពីសិទ្ធិអំណាចរបស់មន្ទីរពាក់ព័ន្ធ អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ និងបែបបទរដ្ឋបាលក្នុងការបញ្ជូនលិខិតណែនាំ ឬបទបញ្ជាស្តីពីការកែកំហុស ។

**មាត្រា ៦ :**

នៅក្នុងរយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែ សម្បទានិកនោះត្រូវបានផ្ដល់ឱកាសចុងក្រោយដើម្បីអនុវត្តតាមការណែនាំ ឬបទបញ្ជារបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឬកែកំហុសរបស់ខ្លួន ។

បន្ទាប់ពីកែកំហុសតាមការណែនាំរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលរួចហើយ សម្បទានិកនោះអាចដាក់សំណើសុំអាជ្ញាប័ណ្ណធនធានរ៉ែដែលត្រូវបានព្យួរទុក និងរបាយការណ៍ពេញលេញស្តីពីការអនុវត្តន៍ការណែនាំ ឬបទបញ្ជានោះព្រមទាំងភស្តុតាងនានាដែលបង្ហាញពីការកែកំហុសរបស់ខ្លួន ជូនទៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដើម្បីពិនិត្យ និងសំរេចឱ្យបានមុនសាមសិប (៣០) ថ្ងៃមុននឹងផុតកំណត់រយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែដែលបានកំណត់នៅក្នុងមាត្រា ៣ ខាងលើ ។

**មាត្រា ៧ :**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរពីការយល់ព្រម ឬការបដិសេធលើសំណើសុំអាជ្ញាប័ណ្ណធនធានរ៉ែដែលត្រូវបានព្យួរទុកនោះ ក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ ចាប់ពីថ្ងៃបានទទួលសំណើសុំអាជ្ញាប័ណ្ណធនធានរ៉ែដែលបានព្យួរទុក និងរបាយការណ៍ពាក់ព័ន្ធបានពេញលេញ ។

**មាត្រា ៨ :**

រយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានគិតបញ្ចូលទៅក្នុងរយៈពេលសពុលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ។

ប្រសិនបើសម្បទានិកបានទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ហើយអាជ្ញាប័ណ្ណធនធានរ៉ែដែលត្រូវបានព្យួរទុកនោះជិតផុត ឬផុតសុពលភាព សម្បទានិកនោះអាចដាក់ពាក្យសុំការពន្យាបន្តអាជ្ញាប័ណ្ណធនធានរ៉ែដោយអនុលោមទៅតាមបទបញ្ញត្តិទាំងឡាយនៃប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**មាត្រា ៩ :**

នៅពេលផុតរយៈពេលនៃការព្យួរទុកអាជ្ញាប័ណ្ណធនធានរ៉ែ ហើយសម្បទានិកនោះនៅតែមិនបានអនុវត្តតាមលក្ខខ័ណ្ឌដូចបានកំណត់ក្នុងមាត្រា ៦ ខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវចេញប្រកាសស្តីពីការដក

ហូតអាជ្ញាប័ណ្ណធនធានរ៉ែជាស្ថាពរពីសម្បទានិក រួចផ្ញើរទៅអាជ្ញាធរខេត្ត-ក្រុងដែលអាជ្ញាប័ណ្ណធនធានរ៉ែនោះស្ថិតនៅ ដើម្បីចាត់វិធានការណ៍ដកហូតអាជ្ញាប័ណ្ណធនធានរ៉ែពីសម្បទានិកនោះ និងបញ្ឈប់ជាស្ថាពរនូវរាល់ការងារ និង សកម្មភាពទាំងអស់នៃប្រតិបត្តិការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ ឬកែឆ្នៃធនធានរ៉ែ ។

**មាត្រា ១០ :**

អាជ្ញាធរខេត្ត-ក្រុងដែលពាក់ព័ន្ធត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលអំពីលទ្ធផលនៃការចាត់វិធានការណ៍ទាំងនោះ ។ ក្នុងករណីចាំបាច់ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវចាត់(បង្កើត) គណៈកម្មការចំរុះដើម្បីចុះទៅធ្វើការព្យួរទុក ឬដកហូតអាជ្ញាប័ណ្ណធនធានរ៉ែពីសម្បទានិកដែលមានការពាក់ព័ន្ធ ព្រមទាំងបិទជាបណ្តោះអាសន្ន ឬបញ្ឈប់ជាស្ថាពរនូវរាល់ការងារ និងសកម្មភាពទាំងអស់នៃប្រតិបត្តិការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ ឬកែឆ្នៃធនធានរ៉ែនោះ ។

**មាត្រា ១១ :**

លោក ប៉េង ណាវុធ ទទួលភារៈកិច្ចរៀបចំកែសម្រួលខ្លឹមសារនៃមាត្រានេះ ។

ក្នុងករណីមានការដកហូតអាជ្ញាប័ណ្ណធនធានរ៉ែជាស្ថាពរពីសម្បទានិកដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងបន្ថែមទៅលើអាជ្ញាប័ណ្ណធនធានរ៉ែនោះជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល កិច្ចព្រមព្រៀងនោះក៏ត្រូវបញ្ចប់ជាស្វ័យប្រវត្តិ ។

**មាត្រា ១២ :**

សម្បទានិកដែលត្រូវបានព្យួរទុក ឬដកហូតអាជ្ញាប័ណ្ណធនធានរ៉ែទោះជាស្ថិតនៅ ឬមិនស្ថិតនៅក្រោមកិច្ចព្រមព្រៀងបន្ថែមទៅលើអាជ្ញាប័ណ្ណធនធានរ៉ែនោះជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវទទួលខុសត្រូវក្នុងការទូទាត់បំណុលជូនរដ្ឋឱ្យចប់សព្វគ្រប់ ដែលរួមមានការបង់សួយសារ ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញ ពន្ធអាករពាក់ព័ន្ធ និងបំណុលផ្សេងទៀតដែលនៅសល់ព្រមទាំងត្រូវទទួលខុសត្រូវ *ក្នុងការស្តារការដ្ឋានជីកយករ៉ែ និង បរិស្ថាននៅក្នុងតំបន់មានអាជ្ញាប័ណ្ណធនធានរ៉ែ ឱ្យបានសមស្រប* (រកពាក្យដាក់ឱ្យសម) ។

ក្នុងករណីសម្បទានិកមិនព្រមអនុវត្តនៅក្នុងកំឡុងពេលមួយជាកំណត់ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវចាត់វិធានការណ៍សមស្រប ដោយរៀបចំសំណុំឯកសារពាក់ព័ន្ធទៅនឹងសម្បទានិកនោះ ហើយបញ្ជូនទៅតុលាការដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**មាត្រា ១៣ :**

លោក ប៉េង ណាវុធ ទទួលភារៈកិច្ចរៀបចំកែសម្រួលខ្លឹមសារនៃមាត្រានេះ ។

ការព្យួរទុក ឬការដកហូតអាជ្ញាប័ណ្ណធនធានរ៉ែដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែទាំងឡាយ រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលនិងអាជីវករ ឬក្រុមហ៊ុនរ៉ែដែលមានពីមុន ហើយផ្ទុយទៅនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៤ :**

នីតិវិធីនៃការព្យួរទុក ឬការដកហូតអាជ្ញាប័ណ្ណធនធានរ៉ែដូចមានចែងក្នុងអនុក្រឹត្យនេះ ពុំបានគិតបញ្ចូលអំពីការផាកពិន័យ និងទោសប្បញ្ញត្តិឡើយ ។

**មាត្រា ១៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង និងសម្បទានិកពាក់ព័ន្ធក្នុងវិស័យនេះត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

**កន្លែងទទួល :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

**មាត្រា ២(ថ្មី) ឬមាត្រា ៤ចាស់ :**

ការព្យួរទុក និងការដកហូតអាជ្ញាប័ណ្ណធនធានរ៉ែត្រូវអនុវត្តតាមកម្រិតនៃការប្រព្រឹត្តល្មើសរបស់សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ។ កម្រិតនៃការប្រព្រឹត្តល្មើសរបស់សម្បទានិកត្រូវបែងចែក និងកំណត់ដូចខាងក្រោម :

(១) ធ្វើបុរេសនា ស្វែងរុករក និងជីកយករ៉ែ ក្នុងដីកម្មសិទ្ធិឯកជនដោយគ្មានការអនុញ្ញាត្ត និងបង្កឱ្យមានការប៉ះពាល់ដល់ដំណាំ រុក្ខជាតិ សត្វពាហនៈរបស់ប្រជាពលរដ្ឋ ។

(២) ធ្វើបុរេសនា ស្វែងរុករក និងជីកយករ៉ែក្នុងតំបន់សម្បទានរបស់រដ្ឋ ដោយពុំបានសហការ និងមានការអនុញ្ញាត្តជាមុនពីស្ថាប័នពាក់ព័ន្ធរបស់រដ្ឋផ្សេងៗទៀត ហើយធ្វើឱ្យប៉ះពាល់ដល់តំបន់វប្បធម៌ ព្រៃជំនឿសសនា តំបន់ការពារធនធានធម្មជាតិ តំបន់អភិរក្សសត្វព្រៃ ហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ និងតំបន់ផ្សេងៗទៀត ។

(៣) ជីកយករ៉ែ ឬធ្វើអាជីវកម្មរ៉ែ ស្ថិតនៅក្រៅទីតាំងសម្បទានដែលក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលបានកំណត់ឱ្យ។

(៤) ធ្វើអាជីវកម្មរ៉ែនៅក្នុងទីតាំងសម្បទានរបស់ខ្លួននិងដឹកជញ្ជូនចេញពីទីតាំងការដ្ឋានដោយពុំបានធ្វើការកំណត់សួយសារពីគណៈកម្មការចុះវាយតម្លៃនិងកំណត់សួយសារអន្តរក្រសួងជាមុន ។

(៥) លួចធ្វើអាជីវកម្មផ្សេងៗ ក្រោមរូបភាពបុរេសនា និងស្វែងរុករករ៉ែដោយខុសពីទិសដៅកម្មវត្ថុអាជីវកម្ម ។

(៦) ប្រើរសេវផ្ទុះ និងសារធាតុគីមីពុលសំរាប់ប្រព្រឹត្តកម្មរ៉ែឬទាញយករ៉ែ មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដោយបង្កជាសំលេងរំខានដល់ការស្នាក់នៅ និងសុខភាពរបស់ប្រជាពលរដ្ឋ សត្វពាហនៈ និងមច្ឆាជាតិ ។

(៧) បង្ហូរចោលកាកសំណល់រ៉ែ និងសារធាតុគីមីពុលពីរោងចក្រឧស្សាហកម្មរ៉ែចូលទៅក្នុងប្រភពទឹកដែលធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពនិងសុខមាលភាពរបស់ប្រជាពលរដ្ឋ សត្វពាហនៈ និងមច្ឆាជាតិ ។ល។

(៨) មិនអនុញ្ញាត្តឱ្យមន្ត្រីមានសមត្ថកិច្ចចូលធ្វើការត្រួតពិនិត្យរាល់ការងារ សកម្មភាពប្រតិបត្តិការធនធានរ៉ែនៅក្នុងការដ្ឋានឬតំបន់ប្រតិបត្តិការរ៉ែរបស់ខ្លួន ។

(៩) មិនគោរពតាមកិច្ចព្រមព្រៀង និងបទបញ្ជារបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

(១០) មិនផ្តល់របាយការណ៍ស្តីពីសកម្មភាពប្រតិបត្តិការធនធានរ៉ែ កម្មវិធីការងារ និងថវិកាសំរាប់ចំណាយលើការងារប្រតិបត្តិការរ៉ែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល តាមកាលកំណត់ ។